វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ប្រទេសកម្ពុជាបានជាប់ឈ្មោះក្នុងបញ្ជីជម្រើសទេសចរណ៍លំដាប់ទី២០
- សេដ្ឋកិច្ចហ្វីលីពីនបានធ្លាក់ចុះពីគោលដៅកំណត់របស់រដ្ឋាភិបាល នៅក្នុងឆ្នាំ២០១៩ និង២០២០
- អត្រាការប្រាក់កម្ចីមានទ្រព្យបញ្ចាំកើនឡើង ខណៈដែរការដាក់ពាក្យសុំប្រាក់កម្ចីយឺត ប៉ុន្តែការផ្តល់ហិរញ្ញប្បទានបន្តកើនឡើងនៅសហរដ្ឋអាមេរិក

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជាបានជាប់ឈ្មោះក្នុងបញ្ជីជម្រើសទេសចរណ៍លំដាប់ទី២០

កាលពីសប្តាហ៍មុនប្រទេសកម្ពុជាត្រូវបានបញ្ចូលទៅក្នុង ប្រទេសទាំង២០ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងការធ្វើទស្សនកិច្ច នៅឆ្នាំ២០២០ ។ សម្រាប់អាស៊ីអាគ្នេយ៍ប្រទេសដែលជាប់ក្នុងបញ្ជីរួមមាន៖ ឥណ្ឌូនេស៊ី (លេខ១) ថៃ (លេខ២) ហ្វីលីពីន (លេខ៨) និងវៀតណាម (លេខ១០)។

ប្រទេសកម្ពុជាឈរជាប្រទេសទស្សនកិច្ច និងទេសចរណ៍ (TTCI) សន្ទស្សន៍នៃទស្សនកិច្ច និងទេសចរណ៍ នៃសន្ទស្សន៍សេដ្ឋកិច្ចពិភពលោកក៏បានកើនឡើង ៣ លំដាប់ពីលំដាប់ចំណាត់ថ្នាក់លេខទី១០១ មក លេខ៩៨ ផងដែរ នៅលើពិភពលោកកាលពីឆ្នាំមុន។

កាសែតខ្មែរថាមស៍ បានលើកឡើងថា ការធ្វើឱ្យប្រសើរឡើងនាពេលថ្មីៗនេះអាចបណ្តាលមកពីកិច្ចខិតខំប្រឹងប្រែងរបស់ កម្ពុជាក្នុងការធ្វើពិពិធកម្មឧស្សាហកម្មទេសចរណ៍របស់ខ្លួនទៅឆ្នេរខ្សាច់ អេកូទេសចរណ៍ និងលើការយកចិត្តទុកដាក់ទៅលើប្រាសាទអង្គរវត្ត។

លោក ថោងខុន រដ្ឋមន្រ្តីក្រសួងទេសចរណ៍ បានថ្លែងនៅក្នុងពិព័រណ៍ទេសចរណ៍នាពេលថ្មីៗនេះថា នៅពេលនិយាយអំពីវិស័យទេសចរណ៍កម្ពុជា ពេលនេះ “មានលក្ខខណ្ឌ និង ឱកាសវិនិយោគល្អបំផុតនៅក្នុងតំបន់” ។

## តារាងប្រចាំសប្តាហ៍៖ កំណើន ផ.ស.ស និងកំណើនតាមវិស័យ

តារាងប្រចាំសប្តាហ៍នេះបង្ហាញពីចក្ខុវិស័យសម្រាប់វិស័យនីមួយៗរបស់កម្ពុជា ចាប់ពីឆ្នាំ២០២០ ដល់ ២០២២។ ជារួមកំណើន ផ.ស.ស ត្រូវបានគេរំពឹងថានឹងនៅតែរឹងមាំក្នុងកម្រិត ៧,១% ក្នុងឆ្នាំ២០១៩ ដែលគាំទ្រយ៉ាងសំខាន់ដោយកំណើនខ្ពស់នៃវិស័យឧស្សាហកម្ម រហូតដល់ ១០,៧% ។ ទោះជាយ៉ាងណាក៏ដោយ កំណើននៅក្នុងវិស័យឧស្សាហកម្មនេះ ត្រូវបានគេរំពឹងថានឹងថយចុះ នៅឆ្នាំ២០២០ ហើយនឹងធ្វើឱ្យកំណើន ផ.ស.ស ថយចុះមកនៅ ៦,៥% មុនពេលកើនឡើងម្តងទៀត ចំនួន ៧% នៅឆ្នាំបន្ទាប់។




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### សេដ្ឋកិច្ចហ្វីលីពីនបានធ្លាក់ចុះពីគោលដៅកំណត់របស់រដ្ឋាភិបាល នៅក្នុងឆ្នាំ២០១៩ និង២០២០

យោងតាមចក្ខុវិស័យសេដ្ឋកិច្ចពិភពលោក ដែលចងក្រងដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នាពេលថ្មីៗនេះ កំណើនសេដ្ឋកិច្ចហ្វីលីពីន មិនបានកើនដល់គោលដៅកំណត់របស់ខ្លួន ក្នុងឆ្នាំ២០១៩ នោះទេ។ ការព្យាករណ៍របស់ IMF ថាសេដ្ឋកិច្ចហ្វីលីពីន និងឈានដល់ ៥,៧% ក្នុងឆ្នាំ២០១៩ ដែលមានកំណើនទាបជាងឆ្នាំមុន ដែលមាន ៦%។ IMF ក៏បានកែសម្រួលការព្យាករណ៍របស់ខ្លួនសម្រាប់ឆ្នាំ២០២០ ផងដែរ ពី ៦,៣% មកត្រឹម ៦,២% វិញ ដែលបានចេញផ្សាយនៅក្នុងខែកក្កដា។

រដ្ឋាភិបាលមានគោលបំណងឲ្យកំណើនសេដ្ឋកិច្ច ស្ថិតក្នុងចន្លោះពី ៦% ទៅ ៧% ក្នុងឆ្នាំ២០១៩ ៦,៥% ទៅ ៧,៥% នៅឆ្នាំ២០២០ និង ៧% ទៅ ៨% នៅឆ្នាំ២០២១ និង ២០២២ ។

នៅក្នុងត្រីមាសទី២ សេដ្ឋកិច្ចហ្វីលីពីន បានកើនឡើង ៥,៥% ពោលគឺធ្លាក់ចុះពី ៥,៦% នៅក្នុងត្រីមាសមុន បន្ទាប់ពីការពន្យារពេលការអនុម័តថវិកាឆ្នាំ២០១៩ ដែលរារាំងដល់ការចំណាយរបស់រដ្ឋាភិបាល។

## សេដ្ឋកិច្ចពិភពលោក

### អត្រាការប្រាក់កម្ចីមានទ្រព្យបញ្ចាំកើនឡើង ខណៈដែលការដាក់ពាក្យសុំប្រាក់កម្ចីយឺត ប៉ុន្តែការផ្តល់ហិរញ្ញប្បទាន បន្តកើនឡើងនៅសហរដ្ឋអាមេរិក

អត្រាការប្រាក់មានកិច្ចសន្យាជាមធ្យមសម្រាប់រយៈពេល ៣០ឆ្នាំ ដែលជាកម្ចីមានអត្រាថេរ នៅសហរដ្ឋអាមេរិកបានកើនឡើងដល់ ៣,៩២% កាលពីសប្តាហ៍មុន ពោលគឺកើនឡើងពី ៣,៩% កាលពីសប្តាហ៍មុន នេះបើយោងតាមសមាគមអ្នកទទួលបញ្ចាំ និងរាយការណ៍ដោយសារព័ត៌មាន CNBC ។

ពាក្យសុំប្រាក់កម្ចីមានទ្រព្យបញ្ចាំដើម្បីទិញផ្ទះ បានធ្លាក់ចុះ ៤% ក្នុងសប្តាហ៍នេះ ប៉ុន្តែនៅតែកើនឡើង ១២% បើប្រៀបធៀបនឹងសប្តាហ៍ដដែល ក្នុងឆ្នាំ២០១៨។

ការផ្តល់ហិរញ្ញប្បទានដល់កម្ចីមានទ្រព្យបញ្ចាំ បានបន្តកើនឡើង ដោយកើនពី ៦០,៤% ទៅ ៦២,២% នៃកម្ចីមានទ្រព្យបញ្ចាំ ដែលធ្វើឱ្យចំនួននៃពាក្យសុំប្រាក់កម្ចីមានទ្រព្យបញ្ចាំ កើនឡើងដល់ ០,៥% នៅក្នុងសប្តាហ៍នេះ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ សមតុល្យពាណិជ្ជកម្មនៅហុងកុង ប្រទេសជប៉ុន និងថៃ ផលិតកម្មឧស្សាហកម្មនៅតៃវ៉ាន់ ប្រទេសសឹង្ហបុរី និង និងការសម្រេចចិត្តលើអត្រាការប្រាក់នៅប្រទេសឥណ្ឌូនេស៊ី។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី២១ តុលា ២០១៩</u>

- តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុន សម្រាប់ខែកញ្ញា
- សន្ទស្សន៍ថ្លៃផ្ទះរបស់ចិន សម្រាប់ខែកញ្ញា
- តុល្យភាពពាណិជ្ជកម្មរបស់ថៃ សម្រាប់ខែកញ្ញា
- ការបញ្ជាទិញការនាំចេញរបស់តៃវ៉ាន់ សម្រាប់ខែកញ្ញា
- ការវិនិយោគដោយផ្ទាល់ពីបរទេសរបស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩

<u>ថ្ងៃអង្គារ ទី២២ តុលា ២០១៩</u>

- សន្ទស្សន៍ថ្លៃផលិតរបស់កូរ៉េខាងត្បូង សម្រាប់ខែកញ្ញា
- សមតុល្យថវិការបស់ហ្វីលីពីន សម្រាប់ខែកញ្ញា
- អត្រាអតិផរណារបស់ហុងកុង សម្រាប់ខែកញ្ញា
- អត្រានិកម្មភាពរបស់តៃវ៉ាន់ សម្រាប់ខែកញ្ញា
- ការលក់ផ្ទះដែលមានស្រាប់នៅសហរដ្ឋអាមេរិក សម្រាប់ខែកញ្ញា

<u>ថ្ងៃពុធ ទី២៣ តុលា ២០១៩</u>

- អត្រាអតិផរណារបស់ម៉ាឡេស៊ី សម្រាប់ខែកញ្ញា
- អត្រាអតិផរណារបស់សឹង្ហបុរី សម្រាប់ខែកញ្ញា
- ផលិតកម្មឧស្សាហកម្មរបស់តៃវ៉ាន់ សម្រាប់ខែកញ្ញា

<u>ថ្ងៃព្រហស្បតិ៍ ទី២៤ តុលា ២០១៩</u>

- ការព្យាករណ៍ ផ.ស.ស កម្រិតខ្ពស់របស់កូរ៉េខាងត្បូង សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩
- សន្ទស្សន៍សេដ្ឋកិច្ចនាំមុខរបស់ជប៉ុន សម្រាប់ខែសីហា
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ឥណ្ឌូនេស៊ី
- តុល្យភាពពាណិជ្ជកម្មរបស់ហុងកុង សម្រាប់ខែកញ្ញា
- អត្ថប្រយោជន៍ពីការអត់ការងារធ្វើ ថ្ងៃទី១៩ ខែតុលា

<u>ថ្ងៃសុក្រ ទី២៥ តុលា ២០១៩</u>

- ទំនុកចិត្តអ្នកប្រើប្រាស់នៅកូរ៉េខាងត្បូង សម្រាប់ខែតុលា
- ការវិនិយោគភាគហ៊ុនរបស់ជប៉ុនដោយជនបរទេស ថ្ងៃទី១៩ ខែតុលា
- ការវិនិយោគដោយផ្ទាល់ពីបរទេសរបស់វៀតណាម សម្រាប់ខែតុលា
- ផលិតកម្មឧស្សាហកម្មរបស់សឹង្ហបុរី សម្រាប់ខែកញ្ញា
- និកម្មភាពរបស់សឹង្ហបុរី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩